# តើការតាមដានប្រវត្តិទំនាក់ទំនងមេរោគមានដំណើរការយ៉ាងដូចម្ដេច?

**ការតាមដានប្រវត្តិទំនាក់ទំនងមេរោគគឺជាដំណើរការសាមញ្ញ និងសម្ងាត់មួយដែលត្រូវបានប្រើប្រាស់ដោយមន្ទីរសុខាភិបាលសាធារណៈនានាជាច្រើនទសវត្សមកហើយ ដើម្បីពន្យឺតការរីករាលដាលនៃជំងឺឆ្លង។ អ្នកអាចចូលរួមចំណែក ដោយឆ្លើយសំណួរសាមញ្ញមួយចំនួន។**

- វាជាការសំខាន់ណាស់ដែលអ្នកអាចឆ្លើយតប ប្រសិនបើអ្នកទទួលបានការហៅទូរស័ព្ទ ឬសារជាអក្សរពីនាយកដ្ឋានសុខភាពសាធារណៈ។ ការហៅទូរស័ព្ទអាចបង្ហាញនៅលើទូរស័ព្ទរបស់អ្នកជាអក្សរ “LA PublicHealth” ឬក៏មានលេខ 1-(833) 641-0305។ អ្នកនឹងត្រូវបានសួរអំពីសុខភាពរបស់អ្នក និងទីកន្លែងដែលអ្នកបានទៅ។
- ប្រសិនបើអ្នកទទួលបានសេចក្ដីបង្គាប់របស់មន្ត្រីសុខាភិបាលប្រចាំខោនធី Los Angeles ហើយមិនទាន់ទទួលបានការសម្ភាសន៍អំពីការតាមដានប្រវត្តិទំនាក់ទំនងមេរោគទេនោះ អ្នកត្រូវតែទូរស័ព្ទទៅលេខនៅលើសេចក្ដីបង្គាប់នោះក្នុងចន្លោះពេល 24 ម៉ោង។
- ការសន្ទនាជាមួយបុគ្គលិកសុខភាពសាធារណៈមានលក្ខណៈជាឯកជន។ នេះមានន័យថាព័ត៌មានទាំងឡាយដែលអ្នកចែករំលែកនឹងត្រូវបានរក្សាទុកជាឯកជន (សម្ងាត់)។
- បុគ្គលិករបស់សុខភាពសាធារណៈនឹងឆ្លើយសំណួរណាមួយដែលអ្នកអាចមាន ហើយនិងថែមទាំងផ្ដល់ជូនអ្នកនូវព័ត៌មានដូចជារបៀបធ្វើតេស្តមេរោគ COVID-19 ពេលវេលាដ៏ល្អបំផុតដើម្បីទទួលការចាក់ថ្នាំបង្ការជំងឺ COVID-19 ឬជួយក្នុងការស្វែងរកគ្រូពេទ្យផងដែរ។

## ប្រសិនបើអ្នកទទួលបានលទ្ធផលធ្វើតេស្តជំងឺ COVID-19 ថាវិជ្ជមាន៖



**បុគ្គលិកសុខភាពសាធារណៈនឹងសួរអំពី៖**

1. ទីកន្លែងដែលអ្នកបានទៅដល់។
2. មនុស្សដែលអ្នកនៅជិត នៅពេលអ្នកអាចចម្លងមេរោគបន្តបាន។

- អ្នកនឹងទទួលបានការហៅទូរស័ព្ទ ឬសារជាអក្សរពីសុខភាពសាធារណៈ ដើម្បីបញ្ចប់ការសម្ភាសន៍។ សូមឆ្លើយទូរស័ព្ទនៅពេលអ្នកទទួលបានការហៅទូរស័ព្ទ និង/ឬបំពេញការស្ទង់មតិនៃការសម្ភាសន៍តាមអនឡាញ បន្ទាប់ពីអ្នកបានទទួលសារជាអក្សរ។
- ចំពោះជនដែលអ្នកបានប្រាប់ឈ្មោះទៅកាន់បុគ្គលិកសុខភាពសាធារណៈ: ជននោះនឹងត្រូវទទួលបានការទាក់ទងទៅ ប៉ុន្តែឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់អ្នក ឬក៏ថាអ្នកមានផ្ទុកមេរោគ COVID-19 គឺមិនប្រាប់ទៅជននោះទេ។ ពួកគេនឹងមិនទទួលបានព័ត៌មានអ្វីអំពីអ្នកទេ គ្រាន់តែថាពួកគេត្រូវបានប៉ះពាល់ទៅនឹងជំងឺ COVID-19។

**ដើម្បីស្វែងយល់បន្ថែម សូមមើល *សេចក្ដីណែនាំនៃការនៅដាច់ដោយឡែក***

- សូមស្កេនកូដ QR ឬ
- ចូលទៅកាន់ **ph.lacounty.gov/covidisolation**។

## ប្រសិនបើអ្នកបានប៉ះពាល់ ឬមានទំនាក់ទំនងជាមួយជនណាម្នាក់ដែលមានផ្ទុកមេរោគ COVID-19៖



**បុគ្គលិកសុខភាពសាធារណៈនឹងសួរអំពី៖**

1. ថាតើអ្នកមានរោគសញ្ញានៃជំងឺ COVID-19 ឬក៏អ្នកបានធ្វើតេស្តរួចរាល់ឬនៅ។
2. ទីកន្លែងដែលអ្នកបានទៅដល់។

- ដើម្បីជៀសវាងការភាន់ច្រឡំរវាងព័ត៌មានរបស់អ្នក និងអ្នកដទៃ សូមផ្ដល់ព័ត៌មានរបស់អ្នកឱ្យបានពេញលេញ និងត្រឹមត្រូវ។
- បុគ្គលិកសុខភាពសាធារណៈអាចទូរស័ព្ទទៅអ្នកច្រើនជាងមួយដង ដើម្បីពិនិត្យតាមដានសុខភាពរបស់អ្នក។
- ពួកគេនឹងផ្ដល់ជូនអ្នកនូវព័ត៌មានអំពីជំហានជាបន្តបន្ទាប់ ដោយផ្អែកទៅលើចម្លើយរបស់អ្នក។

**ដើម្បីស្វែងយល់បន្ថែម សូមមើល *សេចក្ដីណែនាំផ្សេងៗសម្រាប់អ្នកដែលមានទំនាក់ទំនងជិតស្និទ្ធ***

- សូមស្កេនកូដ QR ឬ
- ចូលទៅកាន់ **ph.lacounty.gov/covidcontacts**។

County of Los Angeles Public Health

**ph.lacounty.gov/Coronavirus** 4-29-22
**(Cambodian)**